Theology on the Web.org.uk
Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

សំណុំធិកឃ្មុំ ៤/២ (កក្កដា ២០០៣)៖ ៦៧-៧២



*លោក អ៊ួន សិលា*

# ជួបជាមួយលោកគ្រូ សៀង អង់



*លោកគ្រូ សៀង អង់*

លោកគ្រូ សៀង អង់ កើតនៅថ្ងៃទី ១៩ ឧសភា ឆ្នាំ១៩១៨ ក្នុងគ្រួសារកសិករមួយដែលកាន់ជំនឿផ្នែកព្រះពុទ្ធសាសនា នៅក្នុងភូមិឫស្សី ឃុំបារាយណ៍ ស្រុកទ្រាំង ខេត្តតាកែវ ។ គាត់ត្រូវជាកូនរបស់ លោក សៀង ប៉ែត និងអ្នកស្រី អាំ ។ គាត់មានបងប្អូនបង្កើត ៥ នាក់ គឺស្រី ៤ នាក់ និង ប្រុស ១នាក់ ។ គាត់គឺជាកូនទី ៤ ។

នៅឆ្នាំ ១៩៣៤ គាត់បានបួសជាសង្ឃពុទ្ធសាសនាអស់រយៈពេល ៤ វស្សា ។

អរព្រះគុណព្រះជាម្ចាស់ ដែលគាត់មានឱកាសសិក្សាយល់ច្បាស់ផ្នែកពុទ្ធសាសនា លុះដល់ឆ្នាំ ១៩៤២ គាត់បានលាចាកសិក្ខាបទ ។ បន្ទាប់មកបានរៀបការជាមួយ អ្នកស្រី ប៊ុន សុខ ដែលរស់នៅក្នុងភូមិជាមួយគ្នា នៅឆ្នាំ ១៩៤៣ ។ លោកគ្រូបានថ្វាយខ្លួនទទួលជឿព្រះយេស៊ូ ជាមួយ លោកគ្រូ ជុំ ប៉ៀង ដែលជាគ្រូផ្សាយដំណឹងល្អនៅក្នុងនិកាយស៊ីអឹមអេ (C&MA) ។ គាត់បានចូលរៀននៅសាលាព្រះគម្ពីរតាខ្មៅអស់រយៈពេល ៨ឆ្នាំ ។ ក្រោយពីបញ្ចប់ការសិក្សានៅវិទ្យាស្ថានព្រះគម្ពីរនោះរួចមក គាត់បានធ្វើការជាគ្រូផ្សាយដំណឹងល្អជាមួយនិកាយស៊ីអឹមអេ ។

នៅឆ្នាំ១៩៥៤ លោកគ្រូ សៀង អង់ ចេញទៅធ្វើការផ្សាយដំណឹងល្អនៅខេត្ត តា កែវ ។ ការងារបំរើព្រះនៅទីនោះមានការរីកចំរើនយ៉ាងខ្លាំង រហូតដល់មានការចាប់ឃុំខ្លួន ដោយគេនិយាយបង្កាច់លោកគ្រូថា ជាអ្នកបង្អាប់សាសនាព្រះពុទ្ធ ហើយជាអ្នកដែលនាំមនុស្សជាច្រើនឲ្យវង្វេងពីសាសនារបស់ខ្លួន ។ គេបានទាមទារឲ្យគាត់បង់ប្រាក់ចំនួន២,៥០០៛ ។ ប្រាក់សម័យនោះមានតម្លៃច្រើនសន្ធឹកណាស់ ហើយគេបាននិយាយថា បើគ្មានប្រាក់បង់ទេនោះ គេមិនអនុញ្ញាតឲ្យរួចខ្លួនពីការឃុំឃាំងឡើយ ។ ពេលនោះភរិយារបស់គាត់ក៏ខំដើររកខ្ចីលុយពីបងប្អូន ដើម្បីយកទៅបង់ជូនគេតាមពេលដែលគេកំណត់ឲ្យនោះ ។ ប៉ុន្តែអរព្រះគុណព្រះជាម្ចាស់ដែលព្រះអង្គបានធ្វើការអស្ចារ្យក្នុងចិត្តអ្នកដែលទទួលប្រាក់ទាំងអស់នោះ គេហាក់បីដូចជាមានការភ័យខ្លាចយ៉ាងម៉េចមិនដឹងទេ ទើបគេយកប្រាក់ទាំងអស់នោះមកប្រគល់ឲ្យវិញដោយមិនបាត់មួយរៀលសោះ ថែមទាំងនិយាយសុំទោសដល់ លោកគ្រូទៀតផង ។

លុះដល់ឆ្នាំ ១៩៦១ លោកគ្រូចេញទៅបំរើព្រះនៅក្នុងភូមិ ព្រែក ក្រាញ់ ផ្សារស្រែធំ ជើងភ្នំកំចាយ ឃុំទឹកល្អក់ ស្រុកព្រៃនប់ ខេត្តកំពត ។ នៅទីនោះគាត់បានបង្កើតក្រុមជំនុំមួយថ្វាយព្រះអង្គ គឺនៅក្នុងទីរួមខេត្ត កំពត តែម្តង ហើយគាត់បានស្នាក់នៅទីនោះរហូតដល់ឆ្នាំ ១៩៧០ ។

មហាសន្និបាតរបស់គ្រីស្ទបរិស័ទនៅទីក្រុងភ្នំពេញ បានសម្រេចជ្រើសរើសអ្នកស្ម័គ្រចិត្តចេញទៅបំរើព្រះនៅកម្ពុជាក្រោម ។ ពេលនោះ លោកគ្រូបានស្ម័គ្រចិត្តទៅបំរើព្រះនៅខេត្ត ឃ្លាំង កម្ពុជាក្រោម ។ កាលពីមុនពេលចេញទៅមានការសន្យា ពីគណកម្មាធិការកណ្តាលថា នឹងផ្តល់ថវិកាឧបត្ថម្ភប្រចាំខែ តែនៅពេលទៅដល់ទឹកដីថ្មីដែលមិនមែនជាទឹកដីនៃប្រទេសកំណើតរបស់ខ្លួនផង មានការបៀតបៀនផង ថែមទាំងគ្មានថវិកាឧបត្ថម្ភផង (ព្រោះមានបញ្ហាផ្នែកបច្ចេកទេស) ដែលធ្វើឲ្យលោកគ្រូ និងគ្រួសារមានជីវភាពលំបាកលំបិនមែនទែន ។ ពេលនោះគាត់ត្រូវទៅរស់នៅក្នុងភូមិ មនោទេន ស្រុក ព្រែកឫស្សី ខេត្តឃ្លាំង នៅកម្ពុជាក្រោម ។ ដោយសារតែលោកគ្រូធ្លាប់បួសជាសង្ឃផ្នែកព្រះពុទ្ធសាសនា កាលលោកមិនទាន់ទទួលជឿព្រះយេស៊ូនោះ ទើបលោកគ្រូអាចផ្សាយដំណឹងល្អជាមួយនឹងលោកសង្ឃ និងពុទ្ធបរិស័ទខ្មែរក្រោមយ៉ាងងាយស្រួល តែទោះជាយ៉ាងណាក៏ដោយ មានការបៀតបៀនមិនអន់ប៉ុន្មានដែរ ក្នុងឋានៈលោកគ្រូ ជាបេសកជនចេញទៅក្រៅស្រុកទេសរបស់ខ្លួននោះ ។

នៅពេលដែលគាត់ធ្វើការបំរើព្រះនៅទីនោះគ្មានបានទទួលប្រាក់ខែអ្វីទាំងអស់នោះ កាន់តែធ្វើឲ្យគាត់ឃើញព្រះចេស្តារបស់ព្រះជាម្ចាស់ដែលព្រះអង្គបីបាច់ថែរក្សាដល់គ្រួសាររបស់គាត់យ៉ាងល្អ ។ លោកគ្រូតែងតែដឹកនាំកូនៗទាំងអស់ឲ្យមានជំនឿទុកចិត្តដល់ព្រះជាម្ចាស់ ដោយការដឹកនាំគ្រួសារពិចារណាបទគម្ពីរជារៀងរាល់យប់ ដោយលើកយកខគម្ពីរទំនុកតម្កើងជំពូក១ ជំពូក២៣ ជំពូក៩១ និងគម្ពីរម៉ាថាយជំពូក៥ជាដើម យកមក សិក្សា និងកំសាន្តចិត្តដល់កូនៗ ដើម្បីឲ្យកាន់តែទុកចិត្តដល់ព្រះជាម្ចាស់កាន់ តែខ្លាំងឡើងថែមទៀត ។ នៅកម្ពុជាក្រោមមិនសូវសម្បូណ៌ដើមត្នោត ដូចនៅកម្ពុជាភូមិភាគកណ្តាលយើងទេ ។ លោកគ្រូ ប្រកបរបរចិញ្ចឹមជីវិតជា កសិករផង និងធ្វើជាអ្នកឡើងត្នោតផង ។ លោកគ្រូ មានដើមត្នោតមួយដើមដែលចម្ងាយ២គីឡូម៉ែត្រពីកន្លែងដែលលោកគ្រូស្នាក់នៅ ។ ជីវភាពជាអ្នកធ្វើស្រែ និងឡើងត្នោត ដើម្បីផ្គត់ផ្គង់គ្រួសារផង

និងដើម្បីបំរើព្រះផងនោះ មិនមែនជាការងាយស្រួលឡើយ ។ តែព្រះជាម្ចាស់មានព្រះគុណលើសលប់ចំពោះគ្រួសាររបស់លោកគ្រូក្នុងរយៈពេល ៥ឆ្នាំ នៅឯកម្ពុជាក្រោម ។ ដោយសារព្រះគុណព្រះជាម្ចាស់ លោកគ្រូបានបង្កើតក្រុមជំនុំមួយកន្លែងនៅក្នុងខេត្ត ឃ្លាំង ។

លុះដល់ឆ្នាំ ១៩៧៩ ប្រទេសកម្ពុជាយើងត្រូវបានរំដោះឲ្យមានសេរីភាពពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ។ លោកគ្រូបានបញ្ចប់បេសកកម្មបំរើព្រះនៅកម្ពុជាក្រោម ។ លោកគ្រូបានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ ។ នៅពេលដែលលោកគ្រូមកដល់ភ្លាម លោកគ្រូគង្វាល ៤០នាក់ ជំនាន់ជាមួយគ្នានឹងលោកគ្រូនោះ បានទៅនៅជាមួយនឹងព្រះជាម្ចាស់អស់ទៅហើយ គឺមាននៅសល់តែ៤នាក់គត់ ។ លោកគ្រូពីរនាក់សព្វថ្ងៃនៅសហរដ្ឋអាមេរិក និងគ្រូពីរនាក់ទៀតនៅក្នុងប្រទេសខ្មែរ គឺលោកគ្រូ ង៉ូវ វ៉ន និងលោកគ្រូ សៀង អង់ នេះឯង ។ ពេលនោះលោកគ្រូចាប់ផ្តើមប្រមូលសិស្សដែលជាអ្នកជឿចាស់ៗខ្លះ និងផ្សាយដំណឹងល្អថ្មីខ្លះទៀត លោកគ្រូបង្កើតបានក្រុមជំនុំមួយដែលប្រៀបដូចជាផុសចេញពីគំនរផេះ ដែលភ្លើងសង្គ្រាមបានឆេះបន្សុះស្ទើរគ្មានសល់នោះ ។ ដោយយកគំរូតាមស្មារតីលោក នេហេមា លោកគ្រូបានខំធ្វើការបំរើព្រះយ៉ាងអស់អំពីចិត្ត មិនយូរប៉ុន្មាន ក្រុមជំនុំមួយបានកើតឡើងនៅក្នុងភូមិ ព្រែក តាឡុង សង្កាត់ចាក់អង្រែក្រោម ស្រុក មានជ័យ រាជធានីភ្នំពេញ ដោយបានដាក់ឈ្មោះថា "ព្រះវិហារតាខ្មៅ" ។

រហូតដល់ឆ្នាំ ១៩៨២ ក្រោយពីផ្សាយដំណឹងល្អ និងដើរសួរសុខទុក្ខក្រុមជំនុំដោយលួចលាក់ (ព្រោះកាលពីសម័យនោះ ក្រុមជំនុំមិនបានទទួលស្គាល់ជាផ្លូវការពីរដ្ឋាភិបាលនៅឡើយទេ) ។ លោកគ្រូបានធ្វើដំណើរទៅតាមតំបន់ជាយដែនខ្មែរ-ថៃ ដើម្បីស្វែងរកក្រុមជំនុំដែលនៅសល់ពីស្លាប់ក្នុងសម័យសង្គ្រាម ។ ពេលនោះគាត់បានទៅដល់ជំរំខៅអ៊ីដាងក្នុងទឹកដីថៃ ។ គាត់នៅបំរើព្រះទីនោះ ហើយគាត់បានជួបអ្នកបំរើព្រះចាស់ៗនៅទីនោះ ។ ក្រោយ

មកលោកគ្រូក៏មានឈ្មោះចេញទៅប្រទេសទីបី តែលោកគ្រូមិនព្រមទៅដោយមិនចង់ចេញទៅតែម្នាក់ឯងចោលគ្រួសារនៅឯស្រុកខ្មែរផង ហើយដោយស្រឡាញ់ដល់ក្រុមជំនុំដែលកើតឡើងថ្មីផង លោកគ្រូក៏សម្រេចចិត្តវិលត្រឡប់មកភ្នំពេញវិញ នៅឆ្នាំ ១៩៨៤ ។ នៅពេលនោះការបៀតបៀនកាន់តែមានសភាពធ្ងន់ធ្ងរឡើងជាលំដាប់ តែការបៀតបៀននោះមិនអាចបញ្ឈប់លោកគ្រូពីការផ្សាយដំណឹងល្អ និងដើរសួរសុខទុក្ខក្រុមជំនុំឡើយ ។ នៅទីបំផុត រដ្ឋាភិបាលសម័យនោះគេបានឃាត់ខ្លួនគាត់ដោយដាក់គាត់ក្នុងទីឃុំឃាំង ដែលត្រូវជាប់នៅទីនោះពី ៣ ទៅ ៥ឆ្នាំ ។ នៅក្នុងទីឃុំឃាំង លោកគ្រូមានស្មារតីរឹងប៉ឹងតាមគំរូរបស់លោកប៉ូល ឥតមានខ្វល់ព្រួយអ្វីទាំងអស់ ទោះបីជាគេមិនអនុញ្ញាតឲ្យក្រុមជំនុំ និងកូនចៅចូលទៅសួរសុខទុក្ខគាត់ក៏ដោយ ក៏លោកគ្រូនៅតែបន្តនិយាយប្រាប់ពីដំណឹងល្អរបស់ព្រះយេស៊ូដល់អ្នកដែលជាប់ពន្ធនាគារជាមួយគ្នាឥតឈប់ ។ ដោយសារព្រះគុណព្រះ គាត់មិនបានជាប់នៅទីនោះយូរតាមពេលដែលគេកំណត់នោះឡើយ គឺអស់រយៈពេលតែ ១២០ថ្ងៃ ប៉ុណ្ណោះ គាត់ត្រូវទទួលសេរីភាពមកវិញ។

នៅឆ្នាំ ១៩៨៥ លោកព្រឹទ្ធាចារ្យ សៀង អង់ និងភរិយាបានបន្តបង្កើតក្រុមជំនុំរហូតដល់សព្វថ្ងៃ ដែលមានឈ្មោះថា "ព្រះវិហារតាអង់មេត្រីតាខ្មៅ" ។ ក្នុងការងារបំរើព្រះអស់រយៈពេល៤៨ឆ្នាំមកហើយ គ្មានប្រាក់ឧបត្ថម្ភ ឬជំនួយណាមួយពិតប្រាដកឡើយ តែព្រះជាម្ចាស់បានផ្គត់ផ្គង់បីបាច់ថែរក្សាលោកគ្រូព្រមទាំងភរិយារៀងរហូតមក ។ មកទល់ពេលនេះ លោកគ្រូមានជន្មាយុ ៨៤ឆ្នាំ និងភរិយាគាត់មានជន្មាយុ ៧៥ឆ្នាំ ។ លោកទាំងពីរមានកូនទាំងអស់ ៨នាក់ ប្រុស៣នាក់ និងស្រី៥នាក់ ។ នៅជំនាន់ប៉ុល ពត កូនប្រុស២នាក់បានស្លាប់ ហើយកូនស្រីម្នាក់បានស្លាប់នៅប្រទេសអូស្ត្រាលី ។ លោកព្រឹទ្ធាចារ្យ មានចៅ ២២នាក់ និងចៅទួត ៨នាក់ គេទាំងអស់សុទ្ធតែជាអ្នកជឿព្រះយេស៊ូទាំងអស់គ្នា ហើយកូនប្រសាប្រុស៣នាក់របស់គាត់ជាគ្រូគង្វាល ។

ឥឡូវនេះលោកគ្រូអាចារ្យបានចូលនិវត្តន៍ ហើយបានផ្ទេរការងារបំរើព្រះដល់កូនចៅជំនាន់ក្រោយ និងគណៈកម្មការចាស់ទុំក្នុងព្រះវិហារ ដើម្បីបំរើការងារបន្តពីលោកទាំងពីរ ។ នៅក្នុងបច្ចុប្បន្នវ័យរបស់គាត់ទាំងពីរ គឺជាពេលវេលាដ៏សែនសុខជុំមរមនា ដោយសារបានឃើញផលផ្លែនៃការងារបំរើព្រះដែលលោកបានបំពេញកន្លងមក និងបានឃើញកូនចៅច្រើនប្រាំងលូតលាស់ ដោយជំនឿប្រៀបបីដូចជាលំពង់អូលីវលាស់ខៀវខ្ចី នេះជាពរជ័យដែលព្រះជាម្ចាស់បានប្រទានជូនលោកទាំងពីរ ។ នេះជាគំរូមួយដ៏ប្រសើរសំរាប់យើងរាល់គ្នា នៅពេលដែលយើងទុកចិត្តទាំងស្រុងលើការផ្គត់ផ្គង់របស់ព្រះជាម្ចាស់ នោះយើងនឹងមិនខកចិត្តដូចយើងដាក់ការទុកចិត្តរបស់យើងទៅលើមនុស្សណាម្នាក់នោះទេ ។ បើសិនជាលោកគ្រូទុកចិត្តលើមនុស្សតាមដែលពាក្យគេសន្យាកាលពីពេលដែលគាត់ទៅជាបេសកជននៅកម្ពុជាក្រោម ប្រហែលជាគាត់មិនអាចបំរើព្រះបានទេ ។ តែអរព្រះគុណព្រះជាម្ចាស់ដែលលោកទាំងពីរបានទុកចិត្តលើព្រះជាម្ចាស់ជាជាងលើមនុស្ស ទើបការងារបំរើព្រះរបស់លោកទាំងពីរបានទទួលនូវជោគជ័យ អាចឲ្យយើងយកធ្វើជាគំរូបាន។ អាម៉ែន ។



HONEYCOMB 4/2 (July 2003): 73–76



*UON Seila*

# Meet Pastor Seang Aung



*SEANG Aung*

Pastor Seang Aung was born on May 19, 1918. He was raised in a Buddhist farmer's family in Roeusey village, Baray subdistrict, Trang district, Takeo province. His parents are Mr. Seang Beth and Mrs. Am. Pastor Seang Aung has four sisters, and is himself the fourth child in the family.

In 1934 he entered the monkhood, where he remained for eight years. Praise God for giving him this opportunity to learn first hand about the Buddhist faith, because this knowledge would later help him in his evangelistic work. In 1943 he married Bun Sok, who lived in the

same village. He was converted to Christ by a Christian and Missionary Alliance pastor, Chum Beang, and then attended the Bible School in Takhau town, Kandal province, for four years. After graduating he worked as an evangelist with the Christian and Missionary Alliance.

In 1954 Pastor Seang Aung went to evangelize in Takeo province. As a result, many people converted to Christ. The authorities accused him of disgracing Buddhism and inciting people to betray their own religion, and arrested him. He was asked to pay 2,500 riel. In those days that was a high sum, but they said if he did not pay they would not release him. His wife borrowed money from relatives and paid the authorities as the deadline required. But thank God for working miracles in their lives. The authorities seemed frightened, returned the money, and apologized to him.

In 1961 he went to serve the Lord in Prek Kranh village, Psar SreThom KomChay mountain, Toek Laok subdistrict, Prey Nop district, Kampot province. He planted a church there for the Lord, and stayed in Kampot until 1970.

A Christian conference in Phnom Penh decided to send volunteers to work as missionaries in Kampuchea Kraom. He volunteered to serve in Klang province, Kampuchea Kraom. Before he left, the central committee pledged to support him every month. But when he reached this new place that was not his home country he encountered a lot of persecution, and the promised support did not come. His family faced severe hardship. He stayed in MonoTen village, Prek Roeusy subdistrict, Klang province, Kampuchea Kraom. Because of his experience in Buddhism he could share the Good News with the Buddhist monks and people in Kampuchea Kraom very easily, but at the same there was also a lot of persecution.

When he was in Kampuchea Kraom he received no salary from Cambodia, and so entrusted himself to God's provision. God proved to be so faithful in caring for his family. He always encouraged his children to trust God, and he led a Bible study for his family every night before bedtime. He quoted verses from Psalms 1, 23, and 91, and from Matthew 5, to remind his children to put their trust in the Lord. Kampuchea Kraum does not have many palm trees, as does most of Cambodia. He earned his living by farming and climbing palm trees to

collect juice to sell. There was one palm tree about two kilometers from his place. His life of farmer and palm tree climber was not easy, but God provided what he needed and took care of his family during their five years in Kampuchea Kraom. By the grace of God he was able to plant a church in Klang province.

In 1979 Cambodia was delivered from the hand of the Khmer Rouge and the genocidal Pol Pot régime. His mission as missionary in Kampuchea Kraum thus ended, he repatriated to Cambodia. Upon arrival he learned that forty pastors who had graduated from Takhau Bible School had been promoted into glory with God. Only four pastors remained alive. Two are living in the United States, and two in Cambodia—Ngov Vorn and Seang Aung. At that time he started to gather some remnants and new converts, and established one church out of the scratch the war had left us. In the spirit of Nehemiah he worked very hard for the Lord, and before long one church emerged in Prek Talong village, Sangkat Chak Aungre Kraum, Meanchey district, Phnom Penh. He named it "Ta Khau Church."

In 1982 he went to share the gospel and visit some congregations in secret, because in those days the government did not recognize Christianity. Then he traveled to the Thai border area to visit some war remnant Christians. He settled in Kao I Dang camp, Thailand, to serve the Lord, and there met some of his old friends. Eventually he was chosen to resettle in a third country, but refused to go for two reasons: he did not want to go alone, and he did want to leave the church in the midst of troubles. Rather, he decided to return to Phnom Penh in 1984. There he faced tension and more persecutions every day, but they could not stop him from sharing the gospel and visiting churches. At last he was arrested, sentenced to three to five years, and thrown into jail. In prison he did as Paul and refused to worry, even though they banned church members and relatives from visiting him. In jail he still kept telling people about Jesus. By the grace of God he remained in jail only one hundred twenty days.

In 1985 pastor Seang Aung and his wife continued to serve God, and planted a church that today is called "Ta Aung Metrey Takhau Church." In forty-eight years of serving the Lord he never enjoyed regular financial support from any group, but God took care of him and

his family. He is now eighty-four years and his wife seventy-five. They have three sons and five daughters. Two sons died in the Pol Pot régime, and one daughter died in Australia. They have twenty-two grandchildren and four great grandchildren. They all are Christian, and three of his sons-in-law are pastors.

Pastor Seang Aung is retiring as pastor and has given all the responsibilities to his children and the board of elders in the church. He and his wife live with happiness in their old age as they see the fruit of their effort over the past years, and their children and grandchildren maturing in their faith like the sprout of the olive. This is the blessing by which God has honored their hard work and their trust in Him rather than in people. Had he put his trust in people and their pledges while he was in Kampuchea Kraom, he might not have ended up serving God until his old age. Praise God that they both put their trust in the Lord rather than in man. Therefore they have been successful in serving the Lord, and provide us a good example. Amen.

